ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2012, 10:30
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (០៨)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(08)

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម គង់ ស្រ៊ីម ជាប្រធាន |
| | ចៅក្រម Motoo NOGUCHI |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម Agnieszka KLONOWIECKA-MILART |
| | ចៅក្រម ម៉ុង មុនីចរិយា |
| | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម យ៉ា ណារិន |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ |
| ភាសា៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

## សេចក្ដីសង្ខេបសំអាងហេតុនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខឆ្លាមៗរបស់ នួន ជា ប្រឆាំងនឹង សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ

**ជនជាប់ចោទ**
នួន ជា

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE

**សហព្រះរាជអាជ្ញា ÷**
ជា លាង
Andrew CAYLEY

**សហមេធាវីនាំមុខតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី ÷**
ពេជ អង្គ
Elisabeth SIMONNEAU-FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា[1] ប្រឆាំងនឹង“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារសារ E51/3, E82, E88 និង E92)” (“សេចក្តីសម្រេចដែលរងការជំទាស់”)[2] ទៅតាមវិសាលភាពនៃសេចក្តីសម្រេចតាមសំណើរបស់ជនជាប់ចោទ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[3]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលរងការជំទាស់ ដែល *ក្នុងចំណោមនោះ* បានបដិសេធសំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលបានដាក់ជូនដោយជនជាប់ចោទ កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១។

២. នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់បណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសេចក្តីសម្រេចដែលរងការជំទាស់ ដោយអនុលោមតាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុងដែលមានជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ បណ្តឹងសាទុក្ខបកប្រែជាភាសាខ្មែរត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១[4]។

៣. នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួន[5]។

---

1 “បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ” ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E116/1/1 (“បណ្តឹងសាទុក្ខ”)។

2 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E116។

3 សំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E82 (“សំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង”)។

4 អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ (វិសោធនកម្មលើកទី ៧) អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការអនុញ្ញាតឱ្យដាក់បណ្តឹងសាទុក្ខជាភាសាខ្មែរ “ជាលើកដំបូង”។

5 “សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ”(“សារណាតប”) ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E116/1/4 (“សារណាតប”)។ មើលសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យាពេលដើម្បីធ្វើសារណាតបទៅនឹងបណ្តឹង

៤. នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ជនជាប់ចោទ បានដាក់ការឆ្លើយតបរបស់ខ្លួន[6]។

៥. អនុលោមតាមវិធាន ១០៨(៤*ស្ទួន*)(ក) និងវិធាន ១០៨(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើបណ្ដឹងសាទុក្ខនេះ ក្នុងរយៈពេលបីខែ ក្រោយពីបានទទួល"សំណុំរឿងរួមជាមួយនឹងច្បាប់ចម្លងសេចក្ដីសម្រេចដែលមានការបញ្ជាក់ ព្រមទាំងបណ្ដឹងសាទុក្ខភ្លាមៗនីមួយៗ"រួចមក។ សំណុំរឿងនេះ រួមបញ្ចូលនូវឯកសារសម្ងាត់ទាក់ទងនឹងបណ្ដឹងសាទុក្ខនេះ។ ដោយហេតុថា ឯកសារសម្ងាត់ទាំងនេះ ទើបទទួលបាននៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១[7] នោះ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខនេះ ត្រូវចេញត្រឹមថ្ងៃ ច័ន្ទ ទី ៣០ ខែ មករា ឆ្នាំ ២០១២[8]។ ដោយហេតុថា វិធាន ១០៨(៤*ស្ទួន*) នៃវិធានផ្ទៃក្នុងបានអនុញ្ញាត សំអាងហេតុខាងក្រោមរបស់អង្គជំនុំជម្រះតុលាការកំពូល "គឺជាសេចក្ដីសង្ខេបសំអាងហេតុសម្រាប់សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខនេះ" ហើយសំអាងហេតុពេញលេញនឹងចេញនៅពេលបន្ទាប់"ក្នុងពេលឆាប់ៗតាមលទ្ធភាពដែលអាចធ្វើបាន"[9]។

## II. សារណា

<u>**បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ**</u>

---

សាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា តាមវិធាន ១០៤(៤)(ឃ)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E116/1/2/1។

[6] "ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗ របស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១១ ឯកសារ E116/1/5 ("ការឆ្លើយតប")។

[7] វិធាន១០៨(២) នៃវិធានផ្ទៃក្នុង កំណត់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ជូនបណ្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល "ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ គិតពីថ្ងៃដាក់បណ្ដឹងសាទុក្ខ..."។ អង្គជំនុំជម្រះនេះយល់ឃើញថា ការកំណត់ពេលវេលានេះ ចាប់ផ្ដើមគិតពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១១ គឺជា "ថ្ងៃទីមួយនៃប្រតិទិន បន្ទាប់ពីថ្ងៃដែលបានទទួលការជូនដំណឹងពីឯកសារខ្មែរ និងជាភាសាផ្លូវការមួយផ្សេងទៀត នៃ អ.វ.ត.ក" (សម្រាប់ត្រៀមលក្ខណៈនៅក្នុងករណីប្រៀបធៀបគ្នា ដោយមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការឯកសារ)។

[8] អនុលោមតាមវិធាន ៣៩(៣) នៃវិធានផ្ទៃក្នុង នៅពេលពេលវេលាមានកំណត់ ដូចជាករណីបច្ចុប្បន្ននេះ "ផុតកំណត់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាករបស់ប្រជាជនកម្ពុជា" ពេលវេលាកំណត់ទាំងនោះត្រូវតែបន្តដោយស្វ័យប្រវត្តិជាថ្ងៃបម្រើការងារបន្ទាប់វិញ។

[9] វិធាន ១០៨(*ស្ទួន*) (៤) នៃវិធានផ្ទៃក្នុង។

៦. បណ្តឹងសាទុក្ខ បានលើកឡើងនូវទឡ្ហីករណ៍ចំនួនបួនថា សេចក្តីសម្រេចដែលរងការជំទាស់នេះគួរទុកជាមោឃៈពីព្រោះថា ៖ (១) អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារមិនបានផ្តល់មូលដ្ឋានសំអាងហេតុ ក្នុងការបដិសេធលើការទាមទាររបស់ជនជាប់ចោទអំពីការជ្រៀតជ្រែកដែលពាក់ព័ន្ធផ្ទាល់ទៅនឹងសំណុំរឿង ០០២ (២) អង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនត្រឹមត្រូវនូវការចោទប្រកាន់នានាពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងអាចគ្រាន់តែប្រព្រឹត្តទៅតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងបញ្ហានានាដែលខ្លួនទទួលចាត់ការតែប៉ុណ្ណោះ ហើយថា ការចោទប្រកាន់ទាំងនេះពុំមាន "ផលប៉ះពាល់ជាក់ស្តែង" លើកិច្ចដំណើរការនីតិវិធីនានាក្នុងសំណុំរឿង ០០២ នោះទេ (៣) អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការវាយតម្លៃលើឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ក្នុងទំនាក់ទំនងជាមួយការទាមទារពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២ (៤) អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយលើកឡើងថា ភាគីមិនអាចផ្តួចផ្តើមឲ្យមានកិច្ចដំណើរការនីតិវិធីនានាយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងបានទេ។

៧. ជាលទ្ធផល ជនជាប់ចោទស្នើអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់អំណាចដ៏ទូលំទូលាយរបស់ខ្លួនដើម្បីបង្គាប់ឲ្យមានកិច្ចស៊ើបសួរជាសាធារណៈដែលអនុវត្តដោយស្ថាប័នតុលាការឯករាជ្យមួយ ដើម្បីឲ្យកិច្ចស៊ើបសួរនេះ បញ្ចប់ឲ្យបានមុនសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២។ ជនជាប់ចោទក៏បានស្នើបន្ថែមទៀតឲ្យមានសវនាការជាសាធារណៈ[10]។

## សារណាតបរបស់សហព្រះរាជអាជ្ញា

៨. សហព្រះរាជអាជ្ញាលើកឡើងថា ទឡ្ហីករណ៍ទីមួយ និងទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខ គឺមិនអាចទទួលយកបានទេ ដោយហេតុថានៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ មិនមានការលើកឡើងអំពីមូលដ្ឋាន សំអាងហេតុណាមួយទាល់តែសោះ ។ លើសពីនេះទៀត ទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខ "ហាក់ដូចជាបកស្រាយខុសដោយចេតនាអំពីសំអាងហេតុ"របស់អង្គជំនុំជម្រះសាលាដំបូង[11]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា រាល់ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខមិនមានមូលដ្ឋានត្រឹមត្រូវ

---

[10] បណ្តឹងសាទុក្ខ កថាខណ្ឌ ៦៨ ដល់ ៣៨ និង ៤១ ។

[11] សារណាតប កថាខណ្ឌ ១០។

ឡើយ ហើយស្នើអង្គជំនុំជម្រះតុលាការកំពូលធ្វើការសម្រេចដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ[12]។

**<u>ការឆ្លើយតបរបស់ជនជាប់ចោទ</u>**

៩. ជាការឆ្លើយតប ជនជាប់ចោទលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ចពិចារណាអំពីសំណើយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងដោយឯករាជ្យពីអញ្ញត្រកម្ម[13] ដែលលើកឡើងដោយជនជាប់ចោទ ដោយហេតុថា សំណើ និងអញ្ញត្រកម្មទាំងនេះត្រូវបានធ្វើឡើង ដោយអនុលោមតាមបញ្ញត្តិផ្សេងៗដែលចោទជាបញ្ហាច្បាប់ខុសៗគ្នា[14]។

**<u>ការរំលោភលើភាពសម្ងាត់នៃឯកសារ</u>**

១០. នៅក្នុងសារណាតប សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា បណ្តឹងសាទុក្ខហាក់បីដូចជាត្រូវបានផ្សព្វផ្សាយ ដោយរំលោភលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីចំណាត់ប្រភេទឯកសារជាប្រភេទឯកសារសម្ងាត់ ហេតុដូច្នេះហើយ ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់នូវសមត្ថកិច្ចបន្ទាប់បន្សំរបស់ខ្លួន យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក្នុងការស៊ើបអង្កេតអំពីការជ្រៀតជ្រែក*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ដោយដាក់ចេញ"នូវរាល់ចំណាត់ការដែលខ្លួនយល់ឃើញថាសមស្រប ដើម្បីការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីតុលាការ"[15]។ នៅក្នុងការឆ្លើយតប មេធាវីការពារក្តីបញ្ជាក់ថា ខ្លួនបានចែកចាយបណ្តឹងសាទុក្ខជូនដល់"សមាជិកផ្សេងៗជាច្រើននៃសារព័ត៌មានជាតិ និងអន្តរជាតិ"[16]ពីព្រោះការធ្វើដូចនេះ គឺស្របតាមច្បាប់កម្ពុជា ប្រយោជន៍យុត្តិធម៌ និងដើម្បីការពារសិទ្ធិនានារបស់ជនជាប់ចោទ[17]។

## III. សេចក្តីសង្ខេបនៃសំអាងហេតុ

---

[12] សារណាតប កថាខណ្ឌ ៤ និង ១០។

[13] អញ្ញត្រកម្មរួម នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E51/3 ("អញ្ញត្រកម្ម")។

[14] ការឆ្លើយតប កថាខណ្ឌ ២។

[15] សារណាតប កថាខណ្ឌ ៤១-៤៤ ។

[16] ការឆ្លើយតប កថាខណ្ឌ ៦។

[17] ការឆ្លើយតប កថាខណ្ឌ ៦-៧។

00772893



ភាពអាចទទួលយកបានតាមទម្រង់នៃបណ្តឹងសាទុក្ខ

១១. បណ្តឹងសាទុក្ខនេះអាចទទួលយកបានដោយអនុលោមតាមវិធាន ៣៥(៦) និងវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង និងពិតជាបានដាក់តាមពេលវេលាកំណត់។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់។

ទទ្បីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ

១២. ទោះបីជាផ្នែកពាក់ព័ន្ធនៃអញ្ញត្រកម្ម និងសំណើយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង បានផ្អែកស្ទើរតែទាំងស្រុងទៅលើអង្គហេតុដូចគ្នាក៏ដោយ ក៏អញ្ញត្រកម្ម និងសំណើនេះ ត្រូវបានដាក់ដោយអនុលោមតាមបទប្បញ្ញត្តិខុសគ្នាដែរ។ នៅក្នុងអញ្ញត្រកម្មនេះ ជនជាប់ចោទត្រូវបានស្នើឲ្យបង្ហាញថា អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ដែលនាំឲ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធី[18]។ នៅក្នុងសំណើយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ជនជាប់ចោទមានបំណងបង្ហាញថា អង្គហេតុដូចគ្នាទាំងនេះបង្កើតឲ្យមាន"ហេតុផលដែលគួរឲ្យជឿ" ថា មានបុគ្គលម្នាក់អាចជ្រៀតជ្រែកដល់រដ្ឋបាលតុលាការ និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវតែចាប់ផ្តើមកិច្ចស៊ើបសួរលើករណីនៃការជ្រៀតជ្រែកដែលត្រូវបានចោទឡើង ដើម្បីការពារនូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។

១៣. ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទទ្បីករណ៍របស់សហព្រះរាជអាជ្ញា[19]ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលដោយត្រឹមត្រូវនូវការចោទប្រកាន់នានាទាក់ទងផ្ទាល់នឹងសំណុំរឿង ០០២ តាមរយៈការប្រកាសពីភាពមិនអាចទទួលយកបាននូវអញ្ញត្រកម្មទាំងនេះ[20] គឺលើកឡើងខុសចំណុច។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយហេតុថា បានខកខានក្នុងការផ្តល់នូវសំអាងហេតុតាមចំណុចនីមួយៗ សម្រាប់ការច្រានចោលសំណើយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រង់ចំណុចដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទឡើង ដែលមានទំនាក់ទំនងផ្ទាល់

---

18 មើលសេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៦-១៨។

19 សារណាតប កថាខណ្ឌ ១២-២៨។

20 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៧។

ទៅនឹងសំណុំរឿង ០០២។ ដោយផ្អែកតាមសំអាងហេតុខាងក្រោម កំហុសនេះមិនធ្វើឲ្យមោឃៈសេចក្ដីសម្រេចដែលរងការជំទាស់នោះទេ។

<u>ទទ្ទីករណ៍ទីពីរ និងទីបីនៃបណ្ដឹងសាទុក្ខ</u>

១៤. សមត្ថកិច្ចតុលាការលើរឿងក្ដីនៅ អ.វ.ត.ក ត្រូវបានបែងចែកទៅតាមដំណាក់កាលនានានៃរឿងក្ដី។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចនៅក្នុងដំណាក់កាលស៊ើបអង្កេត រីឯអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មានសមត្ថកិច្ចនៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្ដឹងសាទុក្ខ។ ប្រសិនបើអនុវត្តឲ្យបានតឹងរឹងចំពោះសំណើយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ការបែងចែកសមត្ថកិច្ចនេះ អាចនឹងប៉ះពាល់ដល់ការទទួលខុសត្រូវមុខងាររបស់តុលាការក្នុងការធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[21]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បណ្ដឹងសាទុក្ខបច្ចុប្បន្ននេះពិតជាស្ថិតក្នុងវិសាលភាពនៃគោលការណ៍បែងចែកសមត្ថកិច្ចនេះ។ អង្គហេតុដែលចោទឡើងពាក់ព័ន្ធផ្ទាល់ទៅនឹងសំណុំរឿង ០០២[22] ទោះបីជាមិនបានដោះស្រាយនៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់នេះក៏ដោយ ក៏អង្គហេតុទាំងនេះបានក្លាយជាចំណុចវិវាទ និងត្រូវបានពិចារណា ដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះរួចហើយ[23]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនមានសមត្ថកិច្ច ដោះស្រាយបញ្ហានេះទៀតទេ។ បញ្ហាថាតើ ការចោទប្រកាន់ទាំងនេះអាចប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី

---

[21] សូមមើលទស្សនៈរបស់ចៅក្រម Catherine Marchi-Uhel និងចៅក្រម Rowan Downing, បន្ថែមលើ សាលដីកាលើកទីពីរលើបណ្ដឹងឧទ្ធរណ៍ របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី" ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D314/1/12, កថាខណ្ឌ ១០-១២។

[22] បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣(ខ), (គ), (ឃ) និងកថាខណ្ឌ ៤ ៖ ទោះជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ផ្ទុយទៅនឹងការអះអាងរបស់ជនជាប់ចោទ សេចក្ដីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែនដែលមាននៅក្នុងបណ្ដឹងសាទុក្ខ កថាខណ្ឌ ៣(គ) មិនបានលើកឡើងពីសាក្សីសំខាន់ណាមួយជាពិសេស ដូចបានបញ្ជាក់យ៉ាងត្រឹមត្រូវដោយជនជាប់ចោទផ្ទាល់នៅក្នុងសំណើមុនៗរបស់គាត់ (សំណើតាមវិធាន ៣៥ ជាពិសេសសំណើសុំការស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ D254 កថាខណ្ឌ ៦)។

[23] វិធាន៣៥ នៃវិធានផ្ទៃក្នុងជើងទំព័រ ២។ សេចក្ដីសម្រេចទីពីរស្ដីពីបណ្ដឹងសាទុក្ខរបស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំកោះសាក្សី នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ D314/1/12 កថាខណ្ឌ ១ ដល់ ១៧។

ក្នុងសំណុំរឿង ០០២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែរ ឬ យ៉ាងណានោះ គឺមានការពាក់ព័ន្ធទៅនឹងវត្តមាន របស់សាក្សីមួយចំនួនដែលស្នើឡើងដោយមេធាវីការពារក្តី។ បញ្ហានេះនឹងត្រូវដោះស្រាយនៅក្នុងដំណើរ ការជំនុំជម្រះសំណុំរឿង ០០២។

១៥. ចំពោះអង្គហេតុនានាដែលចោទឡើងជាបឋមពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង០០៤[24] ដែលថាមានផលប៉ះពាល់ដល់សំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របតាមឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ស្ថានភាពដែលប្រសើរជាងគេក្នុងការវាយតម្លៃពីផលប៉ះពាល់នៃការចោទប្រកាន់ទាំងនេះលើកិច្ចដំណើរការនីតិវិធី គឺអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មិនមានកំហុសអង្គហេតុ ឬអង្គច្បាប់ ឬកំហុសដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ នៅក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការអះអាងដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ មិនមាន"ផលប៉ះពាល់ជាក់ស្តែង"[25]លើភាពយុត្តិធម៌នៃសំណុំរឿង ០០២ ឡើយ។

១៦. អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ពីការចោទប្រកាន់នានារបស់ជនជាប់ចោទ ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានា សេចក្តីថ្លែងការណ៍ និងឯកសារនានាដែលមិនអាចរកបានដោយអង្គជំនុំជម្រះសាលាដំបូង នៅពេលចេញសេចក្តីសម្រេចដែលរងការជំទាស់នេះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការចោទប្រកាន់ទាំងនេះកំពុងត្រូវបានវិនិច្ឆ័យនាពេលបច្ចុប្បន្នដោយតុលាការជាតិដែលមេធាវីការពារក្តី បានស្នើសុំឱ្យចាប់ផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខតុលាការទាំងនេះ។ លើសពីនេះទៀត ការចោទប្រកាន់ទាំងនេះ គឺជាប្រធានបទនៃដំណើរការការទូតរវាងរាជរដ្ឋាភិបាលកម្ពុជា និងអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជនជាប់ចោទមិនបានបង្ហាញអំពីផលប៉ះពាល់នៃការចោទប្រកាន់ទាំងនេះលើភាពយុត្តិធម៌នៅក្នុងសំណុំរឿង ០០២ ឡើយ។

<u>ទទ្បីករណ៍ទីបួននៃបណ្តឹងសាទុក្ខ</u>

---

[24] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(ឃ), ៥, ៦, ៩, ១០។

[25] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

១៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះមិនមានអង្គហេតុដែលជាមូលដ្ឋាននៅក្នុងសេចក្តីសម្រេចរងការជំទាស់ ដែលចំណុចនេះមិនអាចបកស្រាយដោយសមហេតុផលថា គឺជាការរារាំងដល់ភាគីណាមួយ ក្នុងការស្នើសុំសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយ ដើម្បីចាត់វិធានការដោយឆន្ទានុសិទ្ធិ ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។

<u>ការរំលោភលើភាពសម្ងាត់នៃឯកសារ</u>

១៨. ការផ្សព្វផ្សាយឯកសារសម្ងាត់ដែលបានចាត់ប្រភេទជាឯកសារសម្ងាត់រួចហើយ ប្រសិនបើគ្មានវិមតិសង្ស័យទេ គឺជាបទល្មើស ដោយអនុលោមតាមវិធាន ៣៥(១)(ក)នៃវិធានផ្ទៃក្នុង ដែលអាចនាំឲ្យមានការដាក់ទណ្ឌកម្ម ស្របតាមច្បាប់កម្ពុជា[26] និង/ឬ ជាការរំលោភលើក្រមសីលធម៌វិជ្ជាជីវៈមេធាវី[27]។ បន្ទាប់ពីបានពិចារណាលើអង្គហេតុនេះ ដូចបានបញ្ជាក់ដោយមេធាវីការពារក្តី[28] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា វិធានការសមស្របសម្រាប់មេធាវីការពារក្តី ដែលជាអ្នកត្រូវស្នើសុំដល់អង្គជំនុំជម្រះដែលពាក់ព័ន្ធឲ្យធ្វើចំណាត់ប្រភេទឯកសារដែលពាក់ព័ន្ធនោះ ជាឯកសារសាធារណៈវិញ[29]។

១៩. អង្គជំនុំជម្រះតុលាការកំពូលបារម្ភអំពីការបញ្ជាក់ជាចំហរបស់មេធាវីការពារក្តីដែលថា ខ្លួនបានត្រៀមរួចជាស្រេចក្នុងការមិនអនុវត្តតាមដោយចេតនាចំពោះដីកាដែលដាក់កាតព្វកិច្ចនៅពេលអនាគត និងថាខ្លួន "នៅតែបន្តផ្សព្វផ្សាយព័ត៌មាន ឬសារណានានារបស់ខ្លួន" នៅពេលដែលពិចារណាឃើញថាមានលក្ខណៈស្របទៅនឹងច្បាប់កម្ពុជា និងផលប្រយោជន៍របស់ជនជាប់ចោទ នួន ជា[30]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា មានតែអង្គជំនុំជម្រះពាក់ព័ន្ធប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការសម្រេចថាតើ ឯកសារណាមួយនៅក្នុងសំណុំរឿងត្រូវបានចាត់ប្រភេទជាឯកសារសម្ងាត់ ឬឯកសារ

[26] វិធាន ៣៥(៤)។

[27] វិធាន ៣៥(៥) និងវិធាន ៣៨នៃវិធានផ្ទៃក្នុង។

[28] ការឆ្លើយតប កថាខណ្ឌ ៦។

[29] សេចក្តីណែនាំអនុវត្ត ០០៤/២០០៩ ៖ ចំណាត់ថ្នាក់ និងការគ្រប់គ្រងពត៏មានពាក់ព័ន្ធនឹងសំណុំរឿង ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៩ ("សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់")។

[30] ការឆ្លើយតប កថាខណ្ឌ ៧។

សាធារណៈ និងកែប្រែការចាត់ ប្រភេទនោះ[31]។ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកដល់មេធាវីការពារក្ដីអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពតាមសេចក្ដីបង្គាប់របស់តុលាការ និងការសម្រេចចាត់ប្រភេទឯកសារ[32] និងធ្វើការព្រមានមិនឱ្យមានការផ្សព្វផ្សាយបន្តទៀតនូវព័ត៌មានសម្ងាត់ ឬសម្ងាត់បំផុត ដោយគ្មានការអនុញ្ញាត។ ការផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតបែបនេះនឹងត្រូវចាត់វិធានការដោយអនុលោមតាមវិធាន ៣៥(២) និងវិធាន ៣៨ នៃវិធានផ្ទៃក្នុង[33]។

២០. ទាក់ទងនឹងការរំលោភលើភាពសម្ងាត់នៃឯកសារនៅក្នុងបណ្ដឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនចាប់ផ្ដើមកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះទេ[34]។ ជាងនេះទៀត អង្គជំនុំជម្រះតុលាការកំពូលសម្រេចចាត់ប្រភេទឯកសារឡើងវិញនូវឯកសារទាំងឡាយដែលរួមមាននៅក្នុងបណ្ដឹងសាទុក្ខភ្លាមៗនេះមានដូចជា ឯកសារ E116/1/1 រួមទាំងឧបសម្ព័ន្ធ និង ឯកសារ E116/1/2 និងឯកសារ E116/1/2/1 និងឯកសារ E116/1/4 រួមទាំងឧបសម្ព័ន្ធ និងឯកសារ E116/1/5។

---

31 មើលរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Jović*, IT-95-14 & IT-95-14/2-R77, "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ៣ របស់ ICTY ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ កថាខណ្ឌ ២២។ មើលផងដែរ វិធាន ២២(៤) (មេធាវីមានកាតព្វកិច្ចត្រូវគោរពនៅចំពោះមុខ អ.វ.ត.ក *ក្នុងចំណោមនោះ* មានសេចក្ដីណែនាំអនុវត្តរបស់ អ.វ.ត.ក)។

32 វិធាន ២២(៤) (តម្រូវឱ្យមេធាវីនៅ អ.វ.ត.ក គោរព សេចក្ដីណែនាំងអនុវត្តរបស់ អ.វ.ត.ក)។

33 មើលសេចក្ដីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្ដីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E115/3 កថាខណ្ឌ ៣៩ និងកថាខណ្ឌសម្រេចសេចក្ដីទីបី, ការព្រមានចំពោះការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដែលគ្មានការអនុញ្ញាត្ត ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D314/1/11, ផ្នែកសម្រេចសេចក្ដី។

34 វិធាន ៣៥ ផ្ដល់ឱ្យ ស.ច.ស និងអង្គជំនុំជម្រះនូវអំណាចឆន្ទានុសិទ្ធិដើម្បីដោះស្រាយបញ្ហានៃការជ្រៀតជ្រែកក្នុងរដ្ឋបាលតុលាការដូចមានការបញ្ជាក់ក្នុងកថាខណ្ឌទីមួយ និងកថាខណ្ឌទីពីរ ដែលប្រើប្រាស់កិរិយាស័ព្ទ "អាច"។ មើលផងដែរ នូវរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Nsengimana*, ICTR-01-69-A/ICTR-2010-92, "សាលដីកាលើបណ្ដឹងឧទ្ធរណ៍នៃការជំនុំជម្រះប្រឆាំងនឹងសេចក្ដីសម្រេចពាក់ពន្ធនឹងការទំនាក់ទំនងមិនសមរម្យជាមួយនឹងសាក្សីសម្រាប់ចូលរួមក្នុងការជំនុំជម្រះ", អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ១៧, ២២ (រកឃើញថា កិច្ចដំណើរការនីតិវិធីដែលមានការប្រមាថ មានឆន្ទានុសិទ្ធិ ហើយដូចនេះ អង្គជំនុំជម្រះសាលាដំបូង "អាចបដិសេធមិនចាប់ផ្ដើម [កិច្ចដំណើរការនីតិវិធី] បើទោះបីជាមាន មូលដ្ឋានគ្រប់គ្រាន់ក្នុងរៀបចំកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងបុគ្គលដោយសារតែការប្រមាថនោះក៏ដោយ")។

## IV. ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**បដិសេធ**បណ្តឹងសាទុក្ខនេះ ជាអសារបង់។

**ព្រមានដល់**មេធាវីការពារក្តីមិនឲ្យផ្សព្វផ្សាយបន្តទៀតនូវព័ត៌មានដែលមានចំណាត់ថ្នាក់សម្ងាត់ដោយគ្មានការអនុញ្ញាត។

**ចាត់ប្រភេទឡើងវិញ**នូវឯកសារដែលបានលើកឡើងខាងលើ ជាឯកសារសាធារណៈវិញ[35]។

ដោយអនុលោមតាមវិធាន ១០៨(៤*ស្ទួន*) នៃវិធានផ្ទៃក្នុង សំអាងហេតុពេញលេញនឹងចេញនៅពេលក្រោយឲ្យបានឆាប់តាមការដែលអាចធ្វើទៅបាន។

**រាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

35 មើលកថាខណ្ឌ ២០ ខាងលើ។